# សេចក្តីបន្ថែមនៃនិយាមបែបបទសំរាប់អនុវត្ត
# សកម្មភាពថែទាំតាមផ្ទះ និងតាមសហគមន៍ និងមណ្ឌលយុទ្ធជ័យរីករាយ

## ១. សេចក្តីផ្តើម

សេវាថែទាំតាមផ្ទះ និងតាមសហគមន៍ គឺជាសមាសភាគមួយយ៉ាងសំខាន់នៃកម្មវិធីថែទាំព្យាបាលបន្តសំរាប់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ។ សេវានេះ បានជួយអោយអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ទទួលបាននូវសេវាផ្សេងៗទៀត ដែលចាំបាច់សំរាប់សុខភាពរបស់ពួកគេ មានជាអាទិ៍ សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍, សេវាព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍, សេវាកាត់បន្ថយការចំលងមេរោគអេដស៍ពីម្តាយទៅកូន, និងសេវាព្យាបាលជំងឺរបេងជាដើម ។ មិនតែប៉ុណ្ណោះ សេវាថែទាំតាមផ្ទះ ក៏បានជួយដល់អ្នកផ្សេងៗទៀតនៅក្នុងសហគមន៍ អោយទទួលបាននូវពតិមានត្រឹមត្រូវស្តីអំពីសេវាសុខភាព និងសង្គម, និងជួយជំរុញអោយពួកគេប្រើប្រាស់សេវាទាំងនោះផងដែរ ។ ដូច្នេះ សេវាថែទាំតាមផ្ទះ និងតាមសហគមន៍ មានតួនាទីសំខាន់ណាស់ ក្នុងការជួយអោយសមាជិកសហគមន៍ ប្រើប្រាស់សេវាសុខាភិបាល និងសេវាសង្គមផ្សេងៗ ដែលមាននៅក្នុងសហគមន៍នោះ ។

ដោយទទួលស្គាល់នូវសារៈសំខាន់នៃសេវាថែទាំតាមផ្ទះ និងតាមសហគមន៍ ក្រសួងសុខាភិបាល តាមរយៈមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានសហការ និងផ្តល់ការគាំទ្រដល់សង្គមស៊ីវិលក្នុងការរៀបចំសេវាថែទាំតាមផ្ទះ និងតាមសហគមន៍ ។ មិនតែប៉ុណ្ណោះ ដើម្បីសំរួលដល់ការអនុវត្តន៍សកម្មភាពថែទាំតាមផ្ទះ និងតាមសហគមន៍ អោយមានភាពរលូន ក្រសួងសុខាភិបាល បានរៀបចំនិយាមនៃបែបបទសំរាប់អនុវត្តការងារនេះ ដោយបានផ្តល់ការណែនាំអំពីការរៀបចំយន្តការសំរបសំរួល, ការរៀបចំសមាសភាពក្រុមថែទាំ, ការរៀបចំសំនុំសកម្មភាពថែទាំ, និងការប៉ាន់ស្មានអំពីថវិកាសំរាប់ប្រតិបត្តិការសកម្មភាព ។ ជាក់ស្តែង សេវាថែទាំតាមផ្ទះ មានការរីកចំរើនគួរអោយកត់សំគាល់ ។

បច្ចុប្បន្ននេះ ក្រសួងសុខាភិបាលបាន និងកំពុងពង្រឹងសេវាថែទាំបន្តអោយកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយថែមទៀត ដោយបង្កើតបន្ថែមនូវមណ្ឌលយុវវ័យរីករាយនៅក្នុងមន្ទីរពេទ្យបង្អែកដែលអនុវត្តកម្មវិធីថែទាំបន្ត ដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ និងក្រុមគ្រួសារ ។ ទន្ទឹមនឹងនេះ ការថែទាំព្យាបាលយុវវ័យ ត្រូវបញ្ជ្រាបចូលក្នុងប្រព័ន្ធថែទាំសុខាភិបាលដែលមានស្រាប់នៅតាមមន្ទីរពេទ្យបង្អែកនានា។ ដូចនេះ សេវាថែទាំតាមផ្ទះ ក៏ត្រូវតែពង្រឹង និងកែលំអផងដែរ ដើម្បីអោយសមស្របទៅនឹង តំរូវការ និងភាពរីកចំរើននៃសេវាថែទាំបន្ត ។

## ២៖ សកម្មភាពបន្ថែមនៃសេវាថែទាំតាមផ្ទះ និងតាមសហគមន៍

ដើម្បីធ្វើអោយសេវាថែទាំតាមផ្ទះ កាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយថែមទៀត សេវានេះ នឹងពង្រីកបន្ថែមនូវសកម្មភាពរបស់ខ្លួន ដោយបញ្ចូលនូវសកម្មភាពគាំទ្រចំពោះកុមារងាយរងគ្រោះ (OVC), គាំទ្រចំពោះក្រុមយុវវ័យ (Adolescents), និងគាំទ្រចំពោះសុខភាពមាតា និងទារក (Maternal Newborn Health) ដើម្បីអោយពួកគេ ទទួលបាននូវសេវាបង្ការ និងថែទាំជំងឺអេដស៍ សមស្រប ។

### ២,១ សកម្មភាពគាំទ្រចំពោះកុមារងាយរងគ្រោះ :

- វាយតំលៃតំរូវការនៃការធ្វើតេស្តឈាមរកមេរោគអេដស៍របស់កុមារ
- បញ្ជូនកុមារដែលត្រូវការធ្វើតេស្តឈាមរកមេរោគអេដស៍ ទៅ VCCT
- បញ្ជូនកុមារផ្ទុកមេរោគអេដស៍ ទៅទទួលសេវា OI/ART សំរាប់កុមារ
- បញ្ជូនកុមារផ្ទុកមេរោគអេដស៍ ទៅមណ្ឌលមិត្តជួយមិត្ត (mmm) សំរាប់កុមារ
- តាមដានកុមារដែលទទួលការព្យាបាល OI/ART បន្តពីមន្ទីរពេទ្យ
- វាយតំលៃចំពោះស្ថានភាពជីវភាពរបស់កុមារ និងស្វែងរកជំនួយគាំទ្រសំរាប់ពួកគេ
- លើកកំពស់ការយល់ដឹងអំពីសិទ្ធិកុមារ នៅក្នុងសហគមន៍
- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍ផ្សេងៗ ដើម្បីផ្តល់ការគាំទ្រខាងសង្គមដល់កុមារ និងគ្រួសារ

### ២,២ សកម្មភាពគាំទ្រចំពោះក្រុមយុវវ័យ :

- អប់រំអំពីការបង្ការជំងឺអេដស៍ និងការថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ
- លើកទឹកចិត្តអោយយុវវ័យប្រើប្រាស់សេវាថែទាំសុខភាពសាធារណៈនៅពេលដែលពួកគេមានបញ្ហាសុខភាព
- សហការជាមួយអ្នកស្ម័គ្រចិត្តនៅមណ្ឌលយុវវ័យរីករាយ (Happy Youth Center) ដើម្បីផ្តល់ពត៌មានអំពីសកម្មភាពរបស់មណ្ឌលនេះ។

- លើកទឹកចិត្ត និងបញ្ជូនយុវវ័យមកចូលរួមក្នុងសកម្មភាពនៃមណ្ឌលយុវវ័យរីករាយ
- បញ្ជូនយុវវ័យដែលត្រូវការធ្វើតេស្តឈាមរកមេរោគអេដស៍ ទៅ VCCT
- បញ្ជូនក្មេងជំទង់ដែលមានផ្ទុកមេរោគអេដស៍ ទៅទទួលការព្យាបាលនៅសេវា OI/ART
- តាមដានការព្យាបាល OI/ART បន្តពីមន្ទីរពេទ្យ

**២,៣ សកម្មភាពគាំទ្រចំពោះសុខភាពមាតា និងទារក :**

- ផ្តល់ការអប់រំអំពីសុខភាពមាតា និងទារក និងចំណេះដឹងអំពីមេរោគអេដស៍-ជំងឺអេដស៍
- លើកទឹកចិត្ត និងបញ្ជូនស្ត្រីមានផ្ទៃពោះមកសេវាថែទាំផ្ទៃពោះមុនពេលសំរាល (Antenatal Care)
- ផ្តល់ពត៌មានអំពីសេវាកាត់បន្ថយការចំលងមេរោគអេដស៍ពីម្តាយទៅកូន
- គាំទ្រនិងបញ្ជូនស្ត្រីមានផ្ទៃពោះ ចូលរួមក្នុងកម្មវិធីកាត់បន្ថយការចំលងមេរោគអេដស៍ពីម្តាយទៅកូន
- តាមដាន និងថែទាំសុខភាពមាតា និងទារកដែលទទួលសេវាកាត់បន្ថយការចំលងមេរោគអេដស៍ ពីម្តាយទៅកូន
- បញ្ជូនស្ត្រីមានផ្ទៃពោះទៅកាន់មណ្ឌលសុខភាព,សេវាធ្វើតេស្តឈាមរកមេរោគអេដស៍, និងសេវាពន្យាកំណើត

## ៣. មណ្ឌលយុវវ័យរីករាយ (Happy Youth Center)

មណ្ឌលយុវវ័យរីករាយ នឹងត្រូវបង្កើតឡើងនៅក្នុងបរិវេណមន្ទីរពេទ្យបង្អែក ក្នុងគោលបំណងបង្កើនការចូលរួមរបស់យុវវ័យក្នុងការស្វែងយល់អំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងទទួលបានការថែទាំព្យាបាលជម្ងឺបង្កដោយការរួមភេទ ដើម្បីអោយពួកគេមានសមត្ថភាពបង្ការខ្លួន កុំអោយឆ្លងមេរោគអេដស៍ និងអាចជៀសវាងបាននូវបញ្ហានានាដែលទាក់ទងនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ។

**៣.១. សកម្មភាពរបស់មណ្ឌលយុវវ័យ រីករាយរួមមាន :**

- ផ្តល់ប្រឹក្សាដល់យុវវ័យទាក់ទងនឹងបញ្ហាសុខភាពផ្លូវភេទ, សុខភាពបន្តពូជ, ជាពិសេសគឺជំងឺអេដស៍ និងជម្ងឺកាមរោគ
- អប់រំអំពីសុខភាពផ្លូវភេទ, សុខភាពបន្តពូជ និងការបង្ការកុំអោយឆ្លងមេរោគអេដស៍
- លើកទឹកចិត្តដល់យុវវ័យ អោយផ្លាស់ប្តូរការប្រព្រឹត្តដែលប្រឈមមុខនឹងការឆ្លងជម្ងឺអេដស៍ និងកាមរោគ
- បញ្ជូនយុវវ័យដែលស្ម័គ្រចិត្តធ្វើតេស្តឈាមរកមេរោគអេដស៍ ទៅ VCCT

- បញ្ជូនយុវវ័យដែលមានបញ្ហាសុខភាពទៅកាន់សេវាព្យាបាលសមស្រប
- សហការជាមួយក្រុមថែទាំតាមផ្ទះ ដើម្បីចុះអប់រំ និងតាមដាន យុវវ័យក្នុងសហគមន៍
- ធ្វើការទំនាក់ទំនងជាមួយអង្គការ និងស្ថាប័ននានា ដើម្បីជួយដល់យុវវ័យ

**៣.២ ដើម្បីដំណើរការបាន មណ្ឌលយុវវ័យរីករាយ ត្រូវមាន :**

- អគារមួយដែលមានយ៉ាងហោចណាស់ ៣ បន្ទប់ :
  - បន្ទប់ធំមួយដែលអាចផ្ទុកមនុស្សបានប្រហែល ២០ នាក់ សំរាប់ប្រើប្រាស់ជាបណ្ណាល័យ ដោយមានសំភារៈចាំបាច់ដូចជា តុធំមួយ, កៅអីចំនួនប្រហែល ២០, ទូធំសំរាប់ដាក់សៀវភៅ និងសំភារៈអប់រំផ្សេងៗ
  - បន្ទប់សំរាប់ផ្តល់ប្រឹក្សា ចំនួន ២ មួយសំរាប់យុវជន និងមួយទៀតសំរាប់យុវនារី ដោយបន្ទប់និមួយៗ មានតុ និងកៅអីសំរាប់ផ្តល់ប្រឹក្សា
- អ្នកផ្តល់ប្រឹក្សា ដែលជាយុវវ័យចំនួន ២ នាក់ គឺយុវជនម្នាក់ និងយុវនារីម្នាក់ ( អ្នកផ្តល់ប្រឹក្សាគួរតែមានអាយុប្រហាក់ប្រហែលអតិថិជន)
- អ្នកផ្តល់ប្រឹក្សា ត្រូវតែបានទទួលការបណ្តុះបណ្តាលសមស្រប អំពីការផ្តល់ប្រឹក្សា និង អំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ

## ៤. គំរូថវិកា :

### ៤-១- ថវិកាបន្ថែមសំរាប់សកម្មភាពបន្ថែមរបស់ក្រុមថែទាំតាមផ្ទះ

| **សកម្មភាព** | **ថវិការយៈពេល ១២ ខែសំរាប់១ក្រុម** | **អត្រា** | **កំណត់សំគាល់** |
|---|---|---|---|
| ការគាំទ្រមធ្យោបាយធ្វើដំណើរ សំរាប់ OVC | ៧២០ ដុល្លា | ១,៥ដុល្លា សំរាប់ម្នាក់ (១,៥ដុល្លា x ៤០នាក់ x ១២ខែ) | តំលៃនេះអាចប្រែប្រួលទៅតាមចំនួនកុមារ និង ចំងាយផ្លូវធ្វើដំណើរ ដែលត្រូវបញ្ជូន ។ |
| ការគាំទ្រមធ្យោបាយធ្វើដំណើរ សំរាប់ក្រុមយុវវ័យ | ៤៥០ ដុល្លា | ១,៥ដុល្លា សំរាប់ម្នាក់ (១,៥ដុល្លា x ២៥នាក់ x ១២ខែ) | តំលៃនេះអាចប្រែប្រួលទៅតាមចំនួនយុវវ័យ និង ចំងាយផ្លូវធ្វើដំណើរដែលត្រូវបញ្ជូន ។ |
| ការគាំទ្រមធ្យោបាយធ្វើដំណើរសំរាប់ស្ត្រីមានផ្ទៃពោះ | ៣៦០ ដុល្លា | ១,៥ដុល្លា សំរាប់ម្នាក់ (១,៥ដុល្លា x ២០នាក់ x ១២ខែ) | តំលៃនេះអាចប្រែប្រួលទៅតាមចំនួនស្ត្រី និង ចំងាយផ្លូវធ្វើដំណើរដែលត្រូវបញ្ជូន ។ |
| **សរុប** | **១៥៣០ដុល្លា** | | |

## ៤-២- ថវិកាសំរាប់សកម្មភាពមណ្ឌលយុវវ័យរីករាយ

| សកម្មភាព | ថវិការយៈពេល ១២ | អត្រា | កំណត់សំគាល់ |
|---|---|---|---|
| ការឧបត្ថម្ភសំរាប់អ្នកផ្តល់ប្រឹក្សា | ៩៦០ ដុល្លា | ៤០ដុល្លា សំរាប់ម្នាក់ (៤០ដុល្លា x ២ នាក់ x ១២ខែ) | |
| ការគាំទ្រមធ្យោបាយធ្វើដំណើរសំរាប់អ្នកស្ម័គ្រចិត្តចុះសហគមន៍ | ២៤០ ដុល្លា | ១០ ដុល្លា សំរាប់ម្នាក់ (១០ដុល្លា x ២ នាក់ x ១២ខែ) | |
| ការគាំទ្រសំរាប់សកម្មភាពអប់រំសហគមន៍ | ២៤០ ដុល្លា | ៥ ដុល្លា សំរាប់ការប្រជុំម្តង (៥ដុល្លា x ៤ ប្រជុំ x ១២ខែ) | ការប្រជុំនេះ ធ្វើឡើងរៀងរាល់សប្តាហ៍ សំរាប់យុវវ័យតាមភូមិខុសៗគ្នា ក្នុងសហគមន៍ |
| ការចំណាយក្នុងមណ្ឌលយុវវ័យរីករាយ | ២៤០ដុល្លា | ២០ ដុល្លា/ខែ | ឯកសារ, ប៊ិច, សៀវភៅ, ទឹក ។ល។ |
| **សរុប** | **១៦៨០ដុល្លា** | | |

បានឃើញ និងឯកភាព
អគ្គនាយកបច្ចេកទេសសុខាភិបាល

វេជ្ជ.ឆេព_លន់

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង
ជំងឺអេដស៍ សើស្បែក និង កាមរោគ

វេជ្ជ. មាន_ឈីវុន